**ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី**

**GRAND TWINS INTERNATIONAL (CAMBODIA) PLC.**

PHUM TRA PANG POR, SANGKAT CHOM CHAU, KHAN POSENCHEY, PHNOM PENH CITY, CAMBODIA

TEL: 855-23-890 325 FAX: 855-23-890 326, E-mail: Vuthy.Puong@gmico.com

---

# សេចក្ដីជូនដំណឹង

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី សូមធ្វើការជូនដំណឹងថា កាលពីថ្ងៃទី២៨ខែតុលា ឆ្នាំ២០១៤ សាលាដំបូងរាជធានីភ្នំពេញបានចុះអនុវត្តដីកាសម្រេចរក្សាការពារ ដោយបិទដីកានេះនៅមុខក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- បង្គាប់ឱ្យកម្មករ-និយោជិតទាំងអស់នៃក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូ-ឌា) ភីអិលស៊ី ចូលធ្វើការក្នុងក្រុមហ៊ុនឱ្យទៀងទាត់តាមវេន (រៀងរាល់ម៉ោងធ្វើការ) តាមក្រុម តាមតួនាទី និងភារៈកិច្ចរៀងៗខ្លួនក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង ហើយមិនត្រូវធ្វើសកម្មភាពរាំងរាំង និងប្រើឧបករណ៍សន្ទស័ព្ទ ឬ ធុងបាស់បំពង សំលេងនាំឱ្យរំខានដល់កម្មករ-និយោជិតឯទៀត ឬហាមឃាត់ការដឹកទំនិញសម្ភារចេញ-ចូលរបស់ក្រុមហ៊ុនឡើយ ក្នុងរយៈពេល៤៨ (សែសិបប្រាំបី) ម៉ោង គិតចាប់ពីពេលទទួលបានដំណឹងដីកាសម្រេចនេះ។
- កម្មករ-និយោជិតដែលមិនបានចូលធ្វើការវិញ នៅពេលផុតកំណត់រយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង ហើយគ្មានហេតុផលត្រឹមត្រូវ ចាត់ទុកថាមានកំហុសធ្ងន់។

នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤ កម្មករ-និយោជិតទាំងអស់បានចូលបម្រើការងារជាប្រក្រតីវិញហើយ។

ដោយឡែក នៅព្រឹក ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤វេលាម៉ោង១០និង១៥នាទីក្រុមហ៊ុនបានបើក អង្គប្រជុំផ្ទៃក្នុងរួមមាន ប្រធានក្រុម លេខា អ្នកបកប្រែ ប្រហែលជា៥០០នាក់ ព្រមទាំងមានវត្តមាន មេធាវីក្រុមហ៊ុនចូលរួមផងដែរ។ ហើយលោកមេធាវីបានមានមតិសំណេះសំណាល និងពន្យល់អំពី សេចក្ដីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៥៧/១៤កបអ.ចុះ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤

និង ដីកាសម្រេចរក្សាការពារលេខ ៣២៨"ច"ភពកាចុះ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ របស់សាលារាជធានីភ្នំពេញ និងមានបើកជំហរសួរសំនួរផ្សេងៗដល់សមាជិកអង្គប្រជុំ។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង១១និង២៥នាទីនាថ្ងៃដដែលប្រកបដោយបរិយាកាសរីករាយ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤

GRAND TWINS INTERNATIONAL (CAMBODIA) PLC.
KINGDOM OF CAMBODIA